

# រូបភាព និងសម្ភារៈពីការ រំលោភបំពានផ្លូវភេទកុមារ ឬរូបភាព និងសម្ភារៈអាសអាភាសកុមារ

## និយមន័យ

### រូបភាព និងសម្ភារៈពីការ រំលោភបំពានផ្លូវភេទកុមារ

រូបភាព និងសម្ភារៈពីការ រំលោភបំពានផ្លូវភេទកុមារ (CSAM) ឬ ដែលគេហៅថា រូបភាព និងសម្ភារៈអាសអាភាសកុមារនោះគឺសំដៅលើការបង្ហាញដោយគ្រប់មធ្យោបាយ អំពីកុមារដែលចូលរួមក្នុងសកម្មភាពផ្លូវភេទពិតប្រាកដ ឬលក្ខណៈធ្វើឲ្យស្រើបស្រាល ឬការបង្ហាញកេរ្តិ៍ភេទ ឬផ្នែកផ្សេងទៀតនៃភេទរបស់កុមារ សម្រាប់គោលបំណងបំពេញចំណង់ផ្លូវភេទ។

*[និយមន័យដែលបានប្រើប្រាស់នៅក្នុងពិធីសារដែលជាជម្រើសចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រង់ចំណុចការជួញដូរកុមារ ពេស្យាចារកុមារ និង រូបភាព និងសម្ភារៈអាសអាភាសកុមារ (CRC OPSC)]។*

រូបភាព និងសម្ភារៈពីការ រំលោភបំពានផ្លូវភេទកុមារ (CSAM) ពណ៌នាពីកុមារគ្រប់វ័យ ឬអាយុទាំងអស់ ទាំងក្មេងប្រុស និងក្មេងស្រី ហើយមានកម្រិតធ្ងន់ធ្ងរនៃអំពើរំលោភបំពានខុសៗគ្នាដោយគិតចាប់ពីការបំពានកុមារលក្ខណៈស្រាលដល់លក្ខណៈធ្ងន់ធ្ងរ។

### រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារដែលផលិតដោយកុំព្យូទ័រ

រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារដែលផលិតដោយកុំព្យូទ័រ ឬ រូបភាព និងសម្ភារៈអាសអាភាសកុមារដែលផលិតដោយកុំព្យូទ័រ សំដៅលើសម្ភារៈនានាដែលមិនពិពណ៌នារូបភាពកុមារពិតនោះទេ ប៉ុន្តែពិពណ៌នារូបភាពកុមារដែលប្រព្រឹត្តសកម្មភាពផ្លូវភេទ ឬត្រូវគេរំលោភបំពានជាលក្ខណៈក្រាហ្វិកណាមួយ ដោយរាប់បញ្ចូលទាំងតុក្កតា រូបភាពដែលផលិតដោយកុំព្យូទ័រ រូបភាពដែលគេកែសម្រួល និងការរួមបញ្ចូលគ្នា។

ទោះជារូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារដែលផលិតដោយកុំព្យូទ័រមិនបង្កផលប៉ះចំពោះកុមារជាក់ស្តែងក៏ដោយ ក៏វានៅតែមានគ្រោះថ្នាក់ដដែល ពីព្រោះ (១) វាអាចត្រូវបានគេប្រើប្រាស់ដើម្បីលួងលោមកុមារដើម្បីធ្វើការកេងប្រវ័ញ្ចលើពួកគេ។ (២) វាបន្តឲ្យមានទីផ្សាររូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ (៣) វាអាចបណ្តាលឱ្យមានវប្បធម៌នៃការអត់ឱនចំពោះសកម្មភាពផ្លូវភេទជាមួយកុមារ និងកេងចំណេញពីតម្រូវការរបស់វា។




### គោលការណ៍ច្បាប់

ការប្រព្រឹត្តិខុសច្បាប់៖

- ការ ចូលមើល ឬប្រើ ឬការផ្តល់ឲ្យ;
- ការកាន់កាប់សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន (ឧទាហរណ៍ មិនមែនសម្រាប់ការចែកចាយ ។ល។) ដែលគេស្គាល់ថាជា 'ការកាន់កាប់ធម្មតា';
- ការចែករំលែក ឬការចែកចាយ;
- ការលក់;
- ការផលិតរូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ។

**រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារត្រូវបានចាត់ជាបទល្មើសព្រហ្មទណ្ឌ (ផ្នែកខ្លះ) តាមគោលការណ៍ច្បាប់ ដូចខាងក្រោម៖**

CRC-OPSC: មិនរាប់បញ្ចូលការមើលរូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ, ការកាន់កាប់ធម្មតា និង រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារដែលផលិតដោយកុំព្យូទ័រ។
អនុសញ្ញាទីក្រុងប៊ុយតាប៉ែស: ការរួមបញ្ចូលនិងចាត់រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារដែលផលិតដោយកុំព្យូទ័រជាបទល្មើសព្រហ្មទណ្ឌ។
អនុសញ្ញាទីក្រុងឡានហ្សារ៉ូត: រួមបញ្ចូលនិងចាត់រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារដែលផលិតដោយកុំព្យូទ័រជាបទល្មើសព្រហ្មទណ្ឌ
អនុសញ្ញា ILO 182: គ្រាន់តែចែងអំពីការផលិត រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ តែប៉ុណ្ណោះ
អនុសញ្ញាស្តីពីបទល្មើសលើអ៊ីនធឺណិតរបស់សហគមន៍អាហ្វ្រិក៖ រួមបញ្ចូលនិងចាត់រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារដែលផលិតដោយកុំព្យូទ័រជាបទល្មើសព្រហ្មទណ្ឌ [មិនទាន់អនុវត្តនៅឡើយ]

### ជនល្មើសត្រូវបានជំរុញដោយចំណង់ផ្លូវភេទរបស់ពួកគេ

- ជនល្មើសត្រូវបានជំរុញដោយ **ចំណង់ផ្លូវភេទរបស់ពួកគេ**ចំពោះកុមារ ឬដោយ**ប្រយោជន៍ហិរញ្ញវត្ថុ**;
- ជនល្មើស ធ្វើសកម្មភាព**តែម្នាក់ឯង** ឬជា(ផ្នែកនៃ)**បណ្តាញ**;
- ជនល្មើស ប្រើប្រាស់**ឧបករណ៍ និងកម្មវិធីកុំព្យូទ័រផ្សេងៗ** និង/ឬ **អ៊ីនធឺណិត** ដើម្បីបង្កើត ចូលប្រើ ឬចែករំលែក រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ;
- ពេលខ្លះជនល្មើស ប្រើប្រាស់**វិធីសាស្ត្រនៃការបំប្លែងកូដឬចាក់សោ** ហើយប្រើប្រាស់កម្មវិធីលាក់បាំងច្រើនថែមទៀតតាមអ៊ីនធឺណិត ដើម្បីបិទបាំងការប្រព្រឹត្តិរបស់ពួកគេ និងចៀសវាងការស៊ើបអង្កេតរកឃើញ;
- រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ ដែលរួមបញ្ចូលទាំងការផលិតដោយកុំព្យូទ័រ ពេលខ្លះត្រូវបានប្រើប្រាស់ដោយជនល្មើស ដើម្បី**លួងលោម ឬរៀបចំ**កុមារឱ្យប្រព្រឹត្តសកម្មភាពផ្លូវភេទ។

** សូមមើលតារាងព័ត៌មានអំពីបច្ចេកវិទ្យា និងអ៊ីនធឺណិត*

## តើលោកអ្នកអាចធ្វើអ្វីខ្លះ?

- តស៊ូមតិដើម្បីឲ្យមានគោលការណ៍ច្បាប់ដែលរឹងមាំ ដែលចាត់រាល់គ្រប់ទម្រង់ទាំងអស់នៃសកម្មភាពពាក់ព័ន្ធនឹងរូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារដោយរួមបញ្ចូលទាំងការផលិតដោយកុំព្យូទ័រផងថាជាបទល្មើសព្រហ្មទណ្ឌ។
- តស៊ូមតិដើម្បីឲ្យមានធនធានដែលប្រសើរជាងមុន សម្រាប់មន្ត្រីអនុវត្តច្បាប់ ដូចជាសមត្ថភាព និងឧបករណ៍ស៊ើបអង្កេតតាមដានរូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ និងកំណត់អត្តសញ្ញាណជនរងគ្រោះនានា
- គាំទ្រ និងសហការជាមួយវិស័យឯកជន ដូចជាក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ដើម្បីអនុវត្តគោលនយោបាយ ក្នុងការរារាំងចរាចរណ៍នៃ រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ
- អប់រំ និងបង្កើនការយល់ដឹងអំពី រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ ដែលរួមទាំងហានិភ័យ និងការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាព
- ធ្វើការស្រាវជ្រាវ និងប្រមូលព័ត៌មានពាក់ព័ន្ធ ដើម្បីពង្រឹងការយល់ដឹងអំពីដែនកំណត់ និងលក្ខណៈរបស់រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ
- ធ្វើការរាយការណ៍នៅពេលដែលលោកអ្នកបានឃើញរូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារលើអ៊ីនធឺណិត
- ផ្តល់ជូនជំនួយគាំទ្រ និងការថែទាំជនរងគ្រោះនៃ រូបភាព និងសម្ភារៈពីការរំលោភបំពានផ្លូវភេទកុមារ។

តារាងព័ត៌មានស្តីអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារលើអ៊ីនធឺណិតនេះផលិតដោយអង្គការ ECPAT អន្តរជាតិ។
ឧបត្ថម្ភគាំទ្រសម្រាប់ការបកប្រែភាសា និងផលិតកម្ម ដែលបានផ្តល់ជូនដោយអង្គការ UNICEF។

ecpat unicef unite for children